តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# សេចក្ដីសង្ខេប ស្ដីពី ធុរកិច្ច

- ការបង់ប្រាក់សម្រាប់ការសម្របសម្រួល
- ការផ្ដល់អំណោយ និង បដិសណ្ឋារកិច្ច
- ការរាយការណ៍
- ទំនាស់ផលប្រយោជន៍

លោក ប៉ិច ពិសី
នាយកកម្មវិធីជាន់ខ្ពស់
អង្គការតម្លាភាពកម្ពុជា
piseypech@ticambodia.org

អង្គការតម្លាភាពកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ៣ ផ្លូវ៣៩០ សង្កាត់បឹងកេងកង៣
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២១៤ ៤៣០
គេហទំព័រក្នុងប្រទេស ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org

អង្គការតម្លាភាពកម្ពុជា គឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើនដែលប្តេជ្ញាបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមក អង្គការនេះបានបង្កើតជាស្ថាប័នដ៏រឹងមាំមួយដែលប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងប្រទេស។

យើងធ្វើការជាមួយបុគ្គល និងស្ថាប័នជាច្រើននៅគ្រប់កម្រិត ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

ឯកសារនេះត្រូវបានរៀបរៀងឡើង ក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប និងប្រទេសស៊ុយអែត។ រាល់ខ្លឹមសារក្នុងឯកសារនេះពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬប្រទេសស៊ុយអែតឡើយ។

# មាតិកា


## ផ្នែកទី១
ការបង់ប្រាក់សម្រាប់ការសម្របសម្រួល

I. និយមន័យ
II. ក្របខ័ណ្ឌគតិយុត្តិ
III. គោលនយោបាយ
IV. អត្ថប្រយោជន៍

## ផ្នែកទី២
ការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច

I. និយមន័យ
II. បរិបទប្រទេសកម្ពុជា
III. អត្ថប្រយោជន៍

## ផ្នែកទី៣
ការរាយការណ៍

I. និយមន័យ
II. តួនាទី
III. បរិបទប្រទេសកម្ពុជា

## ផ្នែកទី៤
ទំនាស់ផលប្រយោជន៍

I. និយមន័យ
II. គោលនយោបាយ
III. អត្ថប្រយោជន៍

# ការបង់ប្រាក់សម្រាប់ការសម្របសម្រួល

**សេចក្តីសង្ខេបពីអាជីវកម្ម**

ទម្រង់ដ៏ទូទៅបំផុតមួយនៃអំពើពុករលួយគឺ "ការបង់ប្រាក់សម្រាប់ការសម្របសម្រួល" ដែលជាការផ្តល់សំណូកតិចតួចដើម្បីទទួលបានសេវារដ្ឋាភិបាលទូទៅដែលក្រុមហ៊ុន និងពលរដ្ឋទូទៅមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានដោយមិនចាំបាច់បង់ប្រាក់បន្ថែម។

ការបង់ប្រាក់សម្រាប់ការសម្របសម្រួល គឺជាទម្រង់មួយនៃអំពើពុករលួយដែលបង្កផលប៉ះពាល់ដល់មនុស្សគ្រប់រូប ក្រុមហ៊ុន និងពលរដ្ឋទូទៅ។ ជាយូរមកហើយដែល "ការបង់ប្រាក់សម្រាប់ការសម្របសម្រួល" មិនត្រូវបានគេមើលឃើញថាជាបទឧក្រិដ្ឋ ប៉ុន្តែត្រឹមតែជាឧបករណ៍ដើម្បីជម្នះទម្លាប់នៃការអនុវត្តបែបការិយាធិបតេយ្យ។ បើគ្មានការបង់ប្រាក់សម្រាប់ការសម្របសម្រួល ក្រុមហ៊ុនមិនអាចរត់ឯកសារបានឡើយ។ ការណ៍នេះតែងធ្វើឲ្យមានការពន្យារពេល និងខាតបង់ច្រើន។

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺ ការបង់ប្រាក់សម្រាប់ការសម្របសម្រួលគឺជាករណីលើកលែងក្នុងច្បាប់ស្តីពីការប្រព្រឹត្តអំពើពុករលួយនៅបរទេស របស់សហរដ្ឋអាមេរិក (FCPA)។[1] FCPA ចែងថាការហាមឃាត់ប្រឆាំងនឹងការសូកប៉ាន់ "មិនត្រូវអនុវត្តចំពោះការសម្របសម្រួលឬការពន្លឿនការបង់ប្រាក់ដល់មន្ត្រីបរទេសគណបក្សនយោបាយឬមន្ត្រីបក្ស ក្នុងគោលបំណងពន្លឿន ឬធានាការអនុវត្តការងារទូទៅរបស់រដ្ឋាភិបាលឡើយ"។[2]

ប៉ុន្តែ វិសាលភាពនៃការលើកលែងនេះ មានលក្ខណៈតូចចង្អៀត និងមិនច្បាស់លាស់ឡើយ។ នៅពេលពិនិត្យមើលករណីអំពើពុករលួយបច្ចុប្បន្នក្រោមច្បាប់នេះ គេឃើញថា បច្ចុប្បន្ន អ្វីដែលត្រូវបានទទួលយកជាការលើកលែងទូទៅ គឺជាប្រធានបទនៃការបកស្រាយកាន់តែតឹងតែង។[3] ការបកស្រាយដ៏តឹងតែងនេះបានបង្កើនហានិភ័យផ្លូវច្បាប់សម្រាប់ក្រុមហ៊ុនដែលអនុញ្ញាតឲ្យមាន ការបង់ប្រាក់សម្រាប់ការសម្របសម្រួលក្នុងក្របខ័ណ្ឌគោលនយោបាយរបស់ខ្លួន។ ដើម្បីឲ្យក្រុមហ៊ុនការពារខ្លួនទល់នឹងហានិភ័យផ្លូវច្បាប់ គេគួរមានគោលនយោបាយមួយដែលហាមឃាត់ការបង់ប្រាក់សម្រាប់ការសម្របសម្រួល។ សេចក្តីសង្ខេបស្តីពីធុរកិច្ចនេះ នឹងពន្យល់ពីទស្សនាទាននៃការបង់ប្រាក់សម្រាប់ការសម្របសម្រួល និងផ្តល់ដល់ក្រុមហ៊ុននូវខ្លឹមសារសង្ខេបនៃគោលនយោបាយល្អប្រសើរស្តីពីការបង់ប្រាក់សម្រាប់ការសម្របសម្រួល។

---

1 ច្បាប់ស្តីពីការប្រព្រឹត្តអំពើពុករលួយនៅបរទេស ឆ្នាំ១៩៧៧។
2 ច្បាប់ស្តីពីការប្រព្រឹត្តអំពើពុករលួយនៅបរទេស ឆ្នាំ ១៩៧៧, 15 USC.78dd.2 (B)។
3 http://www.nortonrosefulbright.com/knowledge/publications/12609 0/facilitating-payments

**តើអ្វីជាការបង់ប្រាក់សម្រាប់ការសម្របសម្រួល?**

ការបង់ប្រាក់សម្រាប់ការសម្របសម្រួលគឺជាការផ្តល់សំណូកតិចតួច ដែលគេអាចហៅថា ការបង់ប្រាក់សម្រាប់ការ "សម្របសម្រួល" "ពន្លឿន" ឬ "ភាពងាយស្រួល" ដែលធ្វើឡើងដើម្បីធានា ឬពន្លឿនការអនុវត្តការងារនៃសកម្មភាពជាទម្លាប់ ឬចាំបាច់ ដែលអ្នកបង់ប្រាក់មានសិទ្ធិទទួលបានតាមផ្លូវច្បាប់ ឬសិទ្ធិទទួលបានផ្សេងទៀត។[4]

## ក្របខ័ណ្ឌគតិយុត្តិ

"ការបង់ប្រាក់សម្រាប់ការសម្របសម្រួល" ផ្ទាល់មិនត្រូវកំណត់ច្បាស់ក្នុងច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា (២០១០) ឡើយ។ ប៉ុន្តែមិនបានកំណត់ទឹកប្រាក់ដែលត្រូវបានចាត់ទុកថាជាការស៊ីសំណូកឡើយ។ ការណ៍នេះមានន័យថា ការបង់ប្រាក់សម្រាប់ការសម្របសម្រួល បើទោះជាមានកម្រិតតិចតួចក្តី ក៏អាចចាត់ទុកជាការស៊ីសំណូកក្នុងបរិបទច្បាប់កម្ពុជាបានដែរ។

ជាក់ស្តែង មាត្រា៩៣ នៃច្បាប់ប្រឆាំងអំពើពុករលួយផ្តន្ទាទោស "បទល្មើសពុករលួយតូចតាច" ដោយដាក់ពន្ធនាគារពី០៧ (ប្រាំពីរ)ថ្ងៃដល់០៥ (ប្រាំ) ឆ្នាំ។ ប្រការនេះគួរតែមានលក្ខណៈគ្រប់គ្រាន់ដើម្បីដាស់តឿនដល់ក្រុមហ៊ុន ឲ្យអនុវត្តគោលនយោបាយគ្មានការអត់អោនចំពោះការបង់ប្រាក់សម្រាប់ការសម្របសម្រួល។

ក្រោមច្បាប់ស៊ីសំណូករបស់ចក្រភពអង់គ្លេស (២០១០) ការបង់ប្រាក់សម្រាប់ការសម្របសម្រួលត្រូវបានហាមឃាត់ដាច់ខាត ដោយមិនគិតពីទំហំ និងភាពញឹកញាប់។ ដូចការលើកឡើងកន្លងមក ការបង់ប្រាក់សម្រាប់ការសម្របសម្រួលត្រូវបានលើកលែងក្នុងច្បាប់ FCPA ប៉ុន្តែវិសាលភាពនៃការលើកលែងនេះកាន់តែមានលក្ខណៈតូចចង្អៀត។ សម្រាប់ការសន្និដ្ឋានរួមផ្អែកតាមផ្លូវច្បាប់ ក្រុមហ៊ុនកំពុងប្រឈមនឹងហានិភ័យផ្លូវច្បាប់កាន់តែច្រើនដោយសារតែមានគោលនយោបាយដែលអនុញ្ញាតឲ្យមានការបង់ប្រាក់សម្រាប់ការសម្របសម្រួល។

## គោលនយោបាយស្តីពីការបង់ប្រាក់សម្រាប់ការសម្របសម្រួល

ចំណុចចាប់ផ្តើមសម្រាប់គោលនយោបាយរឹងមាំ ស្តីពីការបង់ប្រាក់សម្រាប់ការសម្របសម្រួលគឺការកំណត់និយមន័យ និងវិសាលភាព ដើម្បីធានាថា បុគ្គលិកនៅគ្រប់កម្រិតបានយល់ដឹងពេញលេញពីការបង់ប្រាក់សម្រាប់ការសម្របសម្រួល។ ចំណុចនេះមានសារសំខាន់ ព្រោះបុគ្គលិកថ្នាក់ក្រោមមានតួនាទីជាកម្លាំងការពារជួរមុខ ហើយពួកគេត្រូវយល់ដឹងពីហានិភ័យផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងការបង់ប្រាក់សម្រាប់ការសម្របសម្រួល។ វាកាន់តែមានសារសំខាន់ក្នុងបរិយាកាសជីវកម្មដូចនៅកម្ពុជា ដែលគេមើលឃើញថា ការបង់ប្រាក់សម្រាប់ការសម្របសម្រួលធ្វើឡើងដើម្បីជំរុញឲ្យមន្ត្រីរដ្ឋាភិបាលបំពេញការងារ ព្រោះពួកគេទទួលបានប្រាក់បៀវត្សរ៍ទាប។

---

[4] គោលការណ៍ពាណិជ្ជកម្មសម្រាប់ការប្រឈមនឹងការសូកប៉ាន់ឆ្នាំ ២០១៣, អង្គការតម្លាភាពអន្តរជាតិ http://www.transparency.org/whatwedo/publication/business_principles_for_countering_bribery

ក្នុងគោលនយោបាយនេះ គួរតែមានយន្តការរាយការណ៍ច្បាស់លាស់ពីសំណើនៃការបង់ប្រាក់សម្រាប់ការសម្របសម្រួល។ ចំណុចនេះនឹងធ្វើឲ្យថ្នាក់គ្រប់គ្រងបានដឹងពីបញ្ហានេះ និងការពារបុគ្គលិកពីកំហុសឆ្គងដែលកើតមានដោយការពន្យារពេល។ ក្រៅពីនេះគួរមានសៀវភៅបញ្ជីសម្រាប់ក្រុមហ៊ុនដើម្បីកត់ត្រារាល់ប្រតិបត្តិការ ឬសំណើបង់ប្រាក់សម្រាប់ការសម្របសម្រួល។ នេះជាវិធីមួយដែលក្រុមហ៊ុនអាចការពារខ្លួនពីហានិភ័យផ្លូវច្បាប់។ ជាអាទិ៍ គេរកឃើញថា ក្រុមហ៊ុនមួយដែលស្ថិតក្រោមវិសាលភាពច្បាប់ FCPA ត្រូវទទួលខុសត្រូវលើការបង់ប្រាក់ដល់មន្ត្រីគយត្រឹមតែ ៥ដុល្លាប៉ុណ្ណោះដោយសារតែការបង់ប្រាក់នេះរងការចោទប្រកាន់ថាកំណត់លក្ខណៈមិនត្រឹមត្រូវក្នុងបញ្ជី និងកំណត់ត្រារបស់ក្រុមហ៊ុនក្នុងទម្រង់ជា "ថ្លៃអន្តរាគមន៍" "កិត្តិយស" "កម្រៃជើងសារ" និង "ថ្លៃសេវា"។[5] នៅពេលមាននីតិវិធីសម្រាប់សៀវភៅបញ្ជី ក្រុមហ៊ុនអាចកាត់បន្ថយហានិភ័យនៃការបង់ប្រាក់សម្រាប់ការសម្របសម្រួល ដែលត្រូវបានលាក់បាំង ឬកំណត់មិនត្រឹមត្រូវក្នុងបញ្ជី។

ដើម្បីឲ្យគោលនយោបាយនេះកាន់តែមានប្រសិទ្ធភាព គឺតម្រូវឲ្យមានការដាក់ទណ្ឌកម្មដែលមានចាប់ពីការព្រមានជាលាយលក្ខណ៍អក្សរ រហូតដល់ការបណ្តេញចេញទៅតាមកម្រិតធ្ងន់ធ្ងរនៃកំហុស។

## អត្ថប្រយោជន៍នៃការមានគោលនយោបាយស្តីពីការបង់ប្រាក់សម្រាប់ការសម្របសម្រួល

មានអត្ថប្រយោជន៍ ៣ សម្រាប់ក្រុមហ៊ុនឯកជន ឬស្ថាប័នដែលមានគោលនយោបាយស្តីពីការបង់ប្រាក់សម្រាប់ការសម្របសម្រួល៖

- ទប់ស្កាត់បុគ្គលិកមិនឲ្យប្រព្រឹត្តខុស ឬអំពើពុករលួយ
- បុគ្គលិកដឹងពីរបៀបដោះស្រាយសំណើបង់ប្រាក់សម្រាប់ការសម្របសម្រួល
- កាត់បន្ថយហានិភ័យផ្លូវច្បាប់ដោយបង្កើនការយល់ដឹងរបស់បុគ្គលិក និងមាននីតិវិធីច្បាស់លាស់។



Phalinn Ooi (Creative Common)

5 ក្នុងបញ្ហាក្រុមហ៊ុន Layne Christensen Co., SEC Admin។ ដំណើរការនីតិវិធីលេខ ៣-១៦២១៦ (ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤)។ មានក្នុងគេហទំព័រ ៖ http://www.sec.gov/litigation/admin/2014/34-73437.pdf។

# ការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច

អំណោយ និងបដិសណ្ឋារកិច្ចមានលក្ខណៈទូទៅក្នុងទំនាក់ទំនងអាជីវកម្ម និងតែងត្រូវបានគេមើលឃើញថាជាវិធីនៃការដឹងគុណ ឬសញ្ញានៃការគោរពចំពោះសមភាគី។ ក្នុងករណីភាគច្រើន អំណោយទាំងនេះស្ថិតក្នុងព្រំដែនកំណត់សមស្របនិង អាចមើលឃើញជាការចំណាយដោយសុទ្ធចិត្តក្នុងអាជីវកម្ម។ គួរឲ្យស្តាយដែលអំណោយ និងបដិសណ្ឋារកិច្ចក៏ត្រូវបានគេប្រើប្រាស់ជាឧបករណ៍លាក់បាំងការសូកប៉ាន់ និងជះឥទ្ធិពលលើមន្ត្រី និងនិយោជិកសាធារណៈផងដែរ។ ការបង្កើនការយល់ដឹង និងការយកចិត្តទុកដាក់លើអំពើពុករលួយ បានផ្លាស់ប្តូរទម្រង់ជាប្រពៃណីនៃការស៊ីសំណូក (លុយក្រោមតុទៅជាការងារកាន់តែស្មុគស្មាញក្រោមរូបភាពជាអំណោយ និងបដិសណ្ឋារកិច្ច។

សេចក្តីសង្ខេបស្តីពីធុរកិច្ចនេះ នឹងផ្តល់ដល់ក្រុមហ៊ុននូវការណែនាំស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច ដោយបង្ហាញពីស្តង់ដា និងគោលការណ៍ណែនាំដែលអាចទទួលយកបានជាអន្តរជាតិសម្រាប់បរិបទកម្ពុជា។

## តើអ្វីជាអំណោយ ? តើអ្វីជាការស៊ីសំណូក ?

ជាទូទៅ គេមិនងាយនឹងញែកអំណោយឲ្យដាច់ពីការស៊ីសំណូកឡើយ។ មជ្ឈដ្ឋានវប្បធម៌ និងច្បាប់ផ្សេងគ្នាមាននិយមន័យខុសៗគ្នា។ ក្រុមហ៊ុននីមួយៗទទួលខុសត្រូវលើការទទួលបានព័ត៌មាន និងការយល់ដឹងចាំបាច់ពីអ្វីដែលអាចទទួលយកបានក្នុងបរិបទរបស់ខ្លួន។ ចំណុចចាប់ផ្តើមដ៏ល្អមួយគឺការកំណត់ថាតើអំណោយត្រូវបានផ្តល់ឲ្យជាលក្ខណៈបុគ្គល ឬក្រុមហ៊ុន។ អំណោយសាជីវកម្មតែងតែជាអំណោយដែលផ្តល់ឲ្យដោយបើកចំហរដោយមានការអនុម័តជាក់លាក់ ឬមិនជាក់លាក់ពីថ្នាក់គ្រប់គ្រងទាំងសងខាង។ ឧទាហរណ៍នៃអំណោយសាជីវកម្ម រួមមានសៀវភៅកំណត់ហេតុសាជីវកម្មប្រតិទិនដាក់លើតុ ប៊ិច និងក្រដាសបកបិទ ព្រមទាំងជ័យភណ្ឌ ឬមេដាយ។

ក្នុងករណីភាគច្រើន អំណោយទាំងនេះមិនត្រូវបានចាត់ទុកជាការស៊ីសំណូកឡើយ។ ប៉ុន្តែ អំណោយផ្ទាល់ខ្លួនគឺជាវត្ថុដែលផ្តល់ឲ្យ ឬទទួលបានដោយបុគ្គល ប្តី/ប្រពន្ធរបស់ខ្លួន ឬតតីយជនផ្សេងទៀតដែលជំនួសមុខឲ្យបុគ្គលនោះ។

## ការផ្តល់អំណោយ និងបដិសណ្ឋារកិច្ចនៅកម្ពុជា

ក្នុងច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា អំណោយគឺជាការស៊ីសំណូក ប្រសិនបើមានការផ្តល់ទ្រព្យសម្បត្តិ ឬសេវា ឬសម្រាប់ជាអត្ថប្រយោជន៍របស់បុគ្គលម្នាក់ និង មិនមែនជាអំណោយយោងតាមទំនៀមទម្លាប់ ឬប្រពៃណី។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) បានកម្រិតអំណោយត្រឹម ២៥ដុល្លា សម្រាប់មន្ត្រី ACU ហើយអំណោយដែលមានតម្លៃលើសពីនេះត្រូវប្រគល់ជូនទៅវិញ។ ក្រៅពីនេះ ACU បានតម្រូវឲ្យមន្ត្រីរបស់ខ្លួនរាយការណ៍ជាមុនពីការញ៉ាំអាហារពេលល្ងាច និង បដិសណ្ឋារកិច្ចក្នុងអាជីវកម្ម។[6] ការកម្រិតនេះអនុវត្តតែចំពោះ ACU មិនចំពោះស្ថាប័នរដ្ឋាភិបាលផ្សេងទៀតឡើយ។ ការផ្តល់អំណោយ និងបដិសណ្ឋារកិច្ចនៅតែជាបញ្ហាចោទនៅកម្ពុជា និងបានធ្វើឲ្យក្រុមហ៊ុនងាយប្រឈមនឹងការក្លាយជាជនរងគ្រោះនៃអំពើពុករលួយ។ ការផ្តល់ប្រាក់សគុណមិនស្របច្បាប់ និងអំណោយដល់មន្ត្រីលទ្ធកម្មមានលក្ខណៈទូទៅបំផុតក្នុងបរិយាកាសអាជីវកម្មនៅកម្ពុជា។

ក្នុងករណីភាគច្រើន អំណោយផ្ទាល់ខ្លួនត្រូវបានផ្តល់ឲ្យដោយគ្មានការអនុម័តជាក់លាក់ពីថ្នាក់គ្រប់គ្រងទាំងសងខាងឡើយ។ គោលនយោបាយ ឬការអនុវត្តសមស្របត្រឹមតែអនុញ្ញាតឲ្យមានការផ្តល់អំណោយសាជីវកម្ម មិនមែនអំណោយជាសាច់ប្រាក់ឬសមមូលនឹងសាច់ប្រាក់ ឬប្រាក់កម្ចីឡើយ។ សម្រាប់ការផ្តល់អំណោយគេមិនត្រូវផ្តល់អំណោយដែលអាចបង្កើតឲ្យទៅជាកាតព្វកិច្ចនោះទេ។ ការណ៍នេះអាចត្រូវបានប្រើប្រាស់ជាគោលការណ៍ទូទៅ និងជាចំណុចចាប់ផ្តើមសម្រាប់គោលនយោបាយស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច។

ការរៀបចំទទួល ឬស្វាគមន៍យ៉ាងកក់ក្តៅចំពោះបុគ្គល ដែលអាចរួមបញ្ចូលការផ្តល់ការកំសាន្តដល់ភ្ញៀវនៅរមណីយដ្ឋាន ភោជនីយដ្ឋាន សន្និបាត ការប្រគុំតន្ត្រី ព្រឹត្តិការណ៍កីឡា និងឱកាសពិសេសផ្សេងទៀត គឺអាចទទួលយកបាន។ ការណ៍នេះគឺអាស្រ័យលើរចនាសម្ព័ន្ធរបៀបវារៈ។ ផ្នែកអាជីវកម្មត្រូវតែសំខាន់ជាងផ្នែកកំសាន្ត។ ឧ. ការចុះទៅរោងចក្ររយៈពេល ១ម៉ោង បូករួមនឹងការស្នាក់នៅសណ្ឋាគារប្រណិត ២ថ្ងៃ ការញ៉ាំអាហារថ្ងៃត្រង់/ពេលល្ងាច ឬការច្រៀងខារ៉ាអូខេដែលត្រូវចំណាយខ្ពស់ និងសំបុត្រពិសេសសម្រាប់ការទស្សនាព្រឹត្តិការណ៍កីឡា គឺមិនអាចទទួលយកបានឡើយ ដោយសារគោលបំណងបដិសណ្ឋារកិច្ចនេះ មិនពាក់ព័ន្ធនឹងអាជីវកម្មទេ ប៉ុន្តែជាការកំសាន្ត។ ជាទូទៅបដិសណ្ឋារកិច្ចមិនពាក់ព័ន្ធផ្ទាល់នឹងអាជីវកម្មឡើយ ពោលគឺភ្ញៀវក្រៅអាជីវកម្មត្រូវបានអញ្ជើញ (មិត្តភក្តិ/គ្រួសារ) ហើយចំណាយលើបដិសណ្ឋារកិច្ចលើសពី ៣០ដុល្លា/ម្នាក់ត្រូវមានការអនុម័តពីថ្នាក់គ្រប់គ្រង។ ជារួម ប្រសិនបើមានចម្ងល់លើបដិសណ្ឋារកិច្ច ឬអំណោយ គេត្រូវបដិសេធ ឬស្នើសុំការអនុម័តពីថ្នាក់គ្រប់គ្រង។

---

6 http://www.phnompenhpost.com/acu-lays-out- rules-receiving-gifts

## បទដ្ឋាន( ស្តង់ដា )អន្តរជាតិស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច

ស្តង់ដាអន្តរជាតិស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច មានក្នុងច្បាប់ស្តីពីអំពើពុករលួយបរទេសរបស់អាមេរិក (FCPA), ច្បាប់ស៊ីសំណូករបស់ចក្រភពអង់គ្លេស, UN Global Compact (UNGC) និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និង ឧក្រិដ្ឋកម្ម (UNODC)។ UNGC និង UNODC បានបង្កើតវគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណែត ( http://thefightagainstcorruption.org/ ) ស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ចដែលបង្ហាញពីការអនុវត្តល្អជាអន្តរជាតិសម្រាប់ការផ្តល់អំណោយ និង បដិសណ្ឋារកិច្ច។

យោងតាម FCPA វត្ថុដែលមានតម្លៃធម្មតា ដូចជា ថ្លៃជិះរថយន្តឈ្នួល ចំណាយសមស្របលើថ្លៃអាហារ និងការកំសាន្ត វត្ថុលើកទឹកចិត្តរបស់ក្រុមហ៊ុន នឹងមិនជះឥទ្ធិពលមិនសមស្របលើមន្ត្រីឡើយ។ ផ្ទុយទៅវិញ ការផ្តល់អំណោយហួសហេតុ (ដូចជា រថយន្តស្ព័រ អាវរោមសត្វ និងវត្ថុប្រណិតផ្សេងទៀត) និងការផ្តល់អំណោយជាវត្ថុតូចៗជារឿយៗ ត្រូវបានចាត់ទុកជាការស៊ីសំណូក។[7] ការស៊ីសំណូកក្រោមច្បាប់ FCPA មិនត្រូវបានកម្រិតត្រឹមសាច់ប្រាក់ ឬការផ្ទេរប្រាក់ទៅគណនីធនាគារបរទេសឡើយ។ អំណោយមួយចំនួន ការធ្វើដំណើរ និងការកំសាន្តអាចបង្កើតជាការទទួលខុសត្រូវ។[8] ការចំណាយសមស្រប និងដោយសុទ្ធចិត្ត គឺមិនចោទជាបញ្ហាឡើយ។ ការណែនាំ និងការកំណត់ការអនុវត្តដោយក្រសួងយុត្តិធម៌លើកឡើងថា សំបុត្រយន្តហោះថ្នាក់ទីមួយ ការស្នាក់នៅសណ្ឋាគារថ្លៃៗ វិស្សមកាលផ្ទាល់ខ្លួន និងអំណោយធំៗ សុទ្ធតែត្រូវបានចាត់ទុកថាមិនសមហេតុផល។ បដិសណ្ឋារកិច្ចដែលអាចទទួលយកបានពាក់ព័ន្ធផ្ទាល់នឹងការដំឡើងឋានៈ ការបង្ហាញ ឬការពន្យល់ពីផលិតផល ឬសេវា ឬការអនុវត្តទៅតាមកិច្ចសន្យាជាមួយរដ្ឋាភិបាលបរទេស ឬទីភ្នាក់ងារខាងលើ។[9]

7 http://www.justice.gov/criminal/fraud/fcpa/cases/ rae-systems/12-10-10rea-systems.pdf

8 http://fcpamericas.com/english/anti-corruption- compliance/gifts-and-hospitality-in-fcpa-compliance-four-cases-for-your-back- pocket/#sthash.GjtYI85W.dpuf

9 https://www.mayerbrown.com/public_docs/Gifts HospandFacPayments-Houston_Jan2010.pdf

យោងតាមច្បាប់ស៊ីសំណូករបស់ចក្រភពអង់គ្លេស អំណោយអាចចាត់ទុកថា មិនមែនជាអំណោយឡើយ ប្រសិនបើនរណាម្នាក់ផ្តល់អ្វីមួយដែលមានតម្លៃជាប្រាក់ ដែលផ្តល់ប្រយោជន៍ដល់អ្នកផ្សេងទៀត ហើយក្នុងសកម្មភាពនេះ មានចេតនាឲ្យបុគ្គលនោះបំពេញមុខងារមិនសមស្រប និងលម្អៀង។ ក្នុងករណីមានការស៊ើបអង្កេតចេតនាញុះញង់ការប្រព្រឹត្តមិនសមស្រប នឹងត្រូវមានការបញ្ជាក់ដើម្បីឈានទៅដល់ការកាត់ទោស។[10] ក្រោមច្បាប់ស៊ីសំណូករបស់ចក្រភពអង់គ្លេស អង្គអយ្យការត្រូវបង្ហាញថា បដិសណ្ឋារកិច្ចមានចេតនាជំរុញការប្រព្រឹត្តដែលស្មើនឹងការរំលោភក្តីដោយរំពឹងថា បុគ្គលម្នាក់នឹងធ្វើសកម្មភាពដោយសុចរិត មិនលម្អៀង ឬយោងតាមគោលជំហរនៃការជឿជាក់។ ចំណុចនេះនឹងត្រូវបានវិនិច្ឆ័យទៅតាមការយល់ឃើញរបស់ចក្រភពអង់គ្លេស។ ច្បាប់នេះបញ្ជាក់ច្បាស់ថា ការចំណាយសមស្របក្នុងអាជីវកម្មគឺអាចទទួលយកបាន។ ការកំសាន្តដោយសុទ្ធចិត្តគឺជាសកម្មភាពស្របច្បាប់ និងធម្មតាក្នុងអាជីវកម្ម ហើយសារៈសំខាន់របស់វាត្រូវបានទទួលស្គាល់ដោយក្របខណ្ឌច្បាប់។[11]

ជារួម បដិសណ្ឋារកិច្ចមិនត្រូវបានហាមឃាត់ក្រោមស្តង់ដាអន្តរជាតិឡើយប្រសិនបើវាជាចំណាយដោយសុទ្ធចិត្តសមស្របក្នុងអាជីវកម្ម។ ក្នុងករណីភាគច្រើនអំណោយផ្ទាល់ខ្លួន ត្រូវបានផ្តល់ដោយគ្មានការអនុម័តជាក់លាក់ពីថ្នាក់គ្រប់គ្រងទាំងសងខាងឡើយ។ ដូចបានផ្តល់អនុសាសន៍ គោលនយោបាយ ឬការអនុវត្តសមស្របត្រឹមតែអនុញ្ញាតឲ្យមានការផ្តល់អំណោយដល់ក្រុមហ៊ុន ដែលមិនមែនអំណោយជាសាច់ប្រាក់ ឬសមមូលនឹងសាច់ប្រាក់ ឬប្រាក់កម្ចីឡើយ។ សម្រាប់ការផ្តល់អំណោយ គេមិនត្រូវផ្តល់អំណោយដែលអាចចងកាតព្វកិច្ចឡើយ។ ការណ៍នេះអាចត្រូវបានប្រើប្រាស់ជាគោលការណ៍ទូទៅ និងជាចំណុចចាប់ផ្តើមសម្រាប់គោលនយោបាយស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច។

10 https://www.saiglobal.com/compliance/resources/whitepapers/gifts-hospitality-bribes.htm

11 ក្នុងបញ្ហាក្រុមហ៊ុន Layne Christensen Co., SEC Admin។ ដំណើរការនីតិវិធីលេខ ៣-១៦២១៦ (ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤) មានក្នុងគេហទំព័រ ៖ http://www.sec.gov/litigation/admin/2014/34-73437.pdf។

## អត្ថប្រយោជន៍នៃការមានគោលនយោបាយស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច

ក្រុមហ៊ុនដែលមានគោលនយោបាយ និងការកម្រិតច្បាស់លាស់ស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ចកំពុងបង្ហាញពីសុចរិតភាពទាំងក្នុង និងក្រៅក្រុមហ៊ុន។ ការមានគោលនយោបាយនេះ នឹងកាត់បន្ថយលទ្ធភាពដែលនិយោជិកក្លាយជាជនរងគ្រោះនៃអំពើពុករលួយ ដោយសារឥទ្ធិពលមិនសមស្រប ព្រោះអំណោយ និងបដិសណ្ឋារកិច្ចអាចត្រូវបានប្រើប្រាស់សម្រាប់ចងកាតព្វកិច្ច។ កាតព្វកិច្ចនេះអាចបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើការធ្វើសេចក្តីសម្រេចចិត្តរបស់និយោជិក ដែលមិនផ្តោតអាទិភាពលើផលប្រយោជន៍ល្អបំផុតរបស់ក្រុមហ៊ុន។ ការមានគោលនយោបាយ ដែលមានការកម្រិតលើការទទួលយកអំណោយក្រុមហ៊ុនដែលមានតម្លៃទាបជាង៣០ដុល្លា ដោយគ្មានការអនុម័តពីថ្នាក់គ្រប់គ្រង នឹងផ្តល់ការសំអាងដល់បុគ្គលិក។ ការណ៍នេះជួយមិនឲ្យនិយោជិកអាម៉ាស់មុខដោយសារការមិនទទួលយកអំណោយ។ ថ្នាក់គ្រប់គ្រងនឹងដឹងលឺកាន់តែច្រើនពីការផ្តល់ ឬទទួលបានអំណោយ និងបដិសណ្ឋារកិច្ចដោយបុគ្គលិក នៅពេលមានគោលនយោបាយដែលមានលក្ខខណ្ឌរាយការណ៍។ ការណ៍នេះនឹងកម្រិតលទ្ធភាពនៃការជះឥទ្ធិពលមិនសមស្រប និងផ្តល់ឱកាសដល់ការបញ្ឈប់អំពើពុករលួយកុំឲ្យកើតឡើង។ គោលនយោបាយរឹងមាំស្តីពីការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច គឺជាជំហានដ៏ល្អឆ្ពោះទៅរកការបង្កើតវប្បធម៌សុចរិតភាព!

# ការរាយការណ៍

ការរាយការណ៍កាន់តែត្រូវបានទទួលស្គាល់ថា ជាឧបករណ៍ដ៏សំខាន់ក្នុងការទប់ស្កាត់ និងកំណត់រកអំពើពុករលួយ និងការប្រព្រឹត្តខុសផ្សេងទៀត។ តាមរយៈការបង្ហាញ ការធ្វើខុសក្នុងស្ថាប័ន អ្នកផ្តល់ព័ត៌មានអាចទប់ស្កាត់ និងកំណត់រកអំពើពុករលួយមុនពេលព័ត៌មាន លេចលឺជាសាធារណៈ។ ការណ៍នេះអាចជួយសង្គ្រោះ កេរ្តិ៍ឈ្មោះអាជីវកម្ម និងការខាតបង់ប្រាក់ដោយសាររឿងអាស្រូវពុករលួយ។ លក្ខណៈសម្ងាត់នៃអំពើពុករលួយមានន័យថា វាអាចមិនលេចឡើងឡើយ លុះត្រាតែករណីនោះត្រូវបានរាយការណ៍ដោយបុគ្គលដែលរកឃើញអំពើពុករលួយក្នុងការងាររបស់ខ្លួន។ ប៉ុន្តែការរាយការណ៍អាចប្រឈមនឹងគ្រោះថ្នាក់៖ អ្នកផ្តល់ព័ត៌មានតែងប្រឈមនឹងហានិភ័យផ្ទាល់ខ្លួន និងវិជ្ជាជីវៈដើម្បីការពារផលប្រយោជន៍ល្អបំផុតរបស់ក្រុមហ៊ុន។ ដោយសារតែការផ្តល់ព័ត៌មាន ពួកគេអាចបាត់បង់ការងារ អនាគត ការងារមិនល្អ និងធ្វើឲ្យជីវិត និងគ្រួសាររបស់ខ្លួនប្រឈមនឹងហានិភ័យ។

សេចក្តីសង្ខេបស្តីពីធុរកិច្ចនេះ នឹងផ្តល់ដល់វិស័យឯកជននូវការណែនាំមួយចំនួនស្តីពីគោលនយោបាយ ឬនីតិវិធីក្នុងការរាយការណ៍។

## តើអ្វីទៅជាការរាយការណ៍?

ការរាយការណ៍ជាការបង្ហាញព័ត៌មានស្តីពី ការប្រព្រឹត្តខុសក្នុងស្ថាប័ន ឬហានិភ័យចំពោះបុគ្គល ឬនីតិបុគ្គលដែលគេជឿថាអាចបង្កជាសកម្មភាព។ គោលដៅចុងក្រោយនៃការផ្តល់ព័ត៌មានសម្រាប់ក្រុមហ៊ុន គឺការការពារផលប្រយោជន៍ និងកេរ្តិ៍ឈ្មោះល្អបំផុតរបស់ក្រុមហ៊ុន។ ការណ៍នេះសម្រេចបាន តាមរយៈការផ្តល់ព័ត៌មានដល់បុគ្គល ឬស្ថាប័នដែលមានគោលជំហរទប់ស្កាត់គ្រោះថ្នាក់ ស៊ើបអង្កេត ឬចាត់វិធានការប្រឆាំងនឹងអ្នកទទួលខុសត្រូវលើការប្រព្រឹត្តខុសទាំងនោះ។[12]

[12] គោលជំហរគោលនយោបាយ ៖ លេខាធិការដ្ឋានអង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០១០។

## ការរាយការណ៍ ក្នុងច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា

មាត្រា ១៣ នៃច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជាចែងថា ត្រូវចាត់វិធានការចាំបាច់ ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្ដល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ។ ប៉ុន្តែក្នុងមាត្រា ៤១ នៃច្បាប់នេះ អ្នកផ្ដល់ព័ត៌មានដែលរាយការណ៍អាចប្រឈមនឹងការគំរាមកំហែងដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល (ប្រហែល ២៥-២៥០ ដុល្លាសហរដ្ឋអាមេរិក) ប្រសិនបើការអះអាងរបស់ពួកគេត្រូវបានគេរកឃើញថាជា ការចោទប្រកាន់មិនត្រឹមត្រូវ។[13] ការសិក្សារបស់អង្គការតម្លាភាពកម្ពុជាបានរកឃើញពីទំនាក់ទំនងគ្នារវាងការគំរាមកំហែងផ្លូវ ច្បាប់នេះ និងកម្រិតទាបនៃការរាយការណ៍។[14] ជាក់ស្ដែងក្នុងការប៉ុនប៉ងបង្កើនការរាយការណ៍ពីករណីអំពើពុករលួយ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមព្រាងច្បាប់ការពារអ្នករាយការណ៍។

អង្គការតម្លាភាពកម្ពុជាទើបតែបានចេញសេចក្ដីសង្ខេបគោលនយោបាយមួយស្ដីពី "ភាពចាំបាច់នៃច្បាប់ល្អប្រសើរស្ដីពីការការពារអ្នករាយការណ៍នៅកម្ពុជា" កាលពីខែមករា ឆ្នាំ ២០១៦។

## តួនាទីរបស់ការរាយការណ៍នៅ ក្នុងការប្រឆាំងអំពើពុករលួយ

អំពើពុករលួយគឺពិបាករកឃើញណាស់ ហើយជាធម្មតាមានតែអ្នកពាក់ព័ន្ធប្រព្រឹត្តិអំពើពុករលួយ ឬបុគ្គលដែលពាក់ព័ន្ធដែលដឹងពីរឿងនេះ។ រនុកក្នុង គឺជាមនុស្សមួយចំនួនតូចដែលអាចរាយការណ៍ពីករណីអំពើពុករលួយ (ពីមុន ឬបច្ចុប្បន្ន) និងកំណត់ហានិភ័យនៃការប្រព្រឹត្តខុសនៅថ្ងៃខាងមុខ។ តាមរយៈការជួយកំណត់រកករណីអំពើពុករលួយ អ្នករាយការណ៍ដើរតួនាទីសំខាន់ ក្នុងការផ្លាស់ប្ដូរវដ្ដនៃការសម្ងាត់ដ៏គ្រោះថ្នាក់ទៅជាវដ្ដនៃគោលការណ៍សីលធម៌។

ការកំណត់រកអំពើពុករលួយ គឺជាបុរេលក្ខខណ្ឌដើម្បីផ្ដួចផ្ដើមការស៊ើបអង្កេត និង ការកាត់ទោស។ ប៉ុន្តែលុះត្រាតែមានការស៊ើបអង្កេតដោយមានប្រសិទ្ធភាពលើករណីពុករលួយទើបគេអាចផ្លាស់ប្ដូរវប្បធម៌នៃអំពើពុករលួយ និងនាំមកនូវវប្បធម៌សុចរិតភាពបាន។ រឿងអាស្រូវស៊ីសំណូក និងពុករលួយធំៗបង្ហាញពីការគ្រោះថ្នាក់ដែលកើតចេញពីការមិនរាយការណ៍ពីការប្រព្រឹត្តខុសឲ្យបានឆាប់រហ័សនៅពេលរកឃើញ។ ប៉ុន្តែភាពតោះតើយការភ័យខ្លាចការសងសឹក និងភាពស្មោះត្រង់ដែលខុស និងវប្បធម៌នៃភាពស្ងៀមស្ងាត់តែងរាំងស្ទះមិនឲ្យអ្នកដែលអាចក្លាយជាសាក្សី និងអ្នករាយការណ៍ផ្ដល់ព័ត៌មាន។[15]

---

13 ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយនៃប្រទេសកម្ពុជាឆ្នាំ ២០១០

14 ការស្ទង់មតិថ្នាក់ជាតិស្ដីពីការយល់ឃើញរបស់យុវជនអំពីអំពើពុករលួយ និងសុចរិតភាពនៅប្រទេសកម្ពុជា ៖ អង្គការតម្លាភាពកម្ពុជាឆ្នាំ ២០១៥

15 គោលជំហរគោលនយោបាយ ៖ លេខាធិការដ្ឋានអង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០១០

## តើអ្វីជាគោលនយោបាយល្អប្រសើរស្តីពីការរាយការណ៍ និងនីតិវិធីសម្រាប់ធុរកិច្ច ?

គោលនយោបាយស្តីពីការរាយការណ៍ គួរជំរុញឲ្យនិយោជិកផ្តល់ព័ត៌មាន ប្រសិនបើពួកគេមានបញ្ហាជាក់លាក់ចំពោះការប្រព្រឹត្តខុស ដែលខុសពីបណ្តឹងសារទុក្ខរបស់បុគ្គល។ គោលនយោបាយនោះគួរបង្កើតជានីតិវិធីដែលអាចទទួលបានសម្រាប់សកម្មភាពនេះ និងអាចជាគោលការណ៍ដាច់ដោយឡែក ឬជាផ្នែកនៃក្រមប្រតិបត្តិទូទៅ។

### គោលនយោបាយល្អប្រសើរស្តីពីការរាយការណ៍គួរៈ

- មានលក្ខណៈសាមញ្ញ និងងាយស្រួលយល់
- គ្របដណ្តប់លើគ្រប់ការងារទាំងអស់
- បញ្ជាក់ច្បាស់ពីស្តង់ដានៃការប្រព្រឹត្តរបស់និយោជិក
- បង្ហាញច្បាស់ពីការគ្របដណ្តប់លើប្រភេទនៃការបង្ហាញព័ត៌មាន ឬ ការប្រព្រឹត្តខុស
- បញ្ជាក់ច្បាស់ពីរបៀប និងបុគ្គលទំនាក់ទំនងនៅពេលមានបញ្ហា (ដូចជា លេខទំនាក់ទំនង)
- អនុញ្ញាតឲ្យនិយោជិកគេចចេញពីបុគ្គល ឬផ្នែកនៃអាជីវកម្មដែលពាក់ព័ន្ធនឹងបញ្ហាកង្វល់នោះ។ បច្ចុប្បន្ន អង្គការជាច្រើនមានខ្សែទូរស័ព្ទផ្តល់ព័ត៌មានសម្ងាត់ដើម្បីធានាទំនុកចិត្ត និងភាពងាយស្រួលរបស់និយោជិកក្នុងការបង្ហាញព័ត៌មាន និងផ្តល់និតិវិធីច្បាស់លាស់
- ត្រូវបង្កើតជំហានពាក់ព័ន្ធក្នុងការស៊ើបអង្កេតលើបញ្ហា និងជំហានដែលអាចធ្វើឡើងនៅពេលមានការប្រព្រឹត្តខុស។
- បង្កើតគោលនយោបាយការពារល្អប្រសើរសម្រាប់អ្នកផ្តល់ព័ត៌មានដោយសុចរិត។



អ្នកមានការបារម្ភ ឬបញ្ហាស្តីពីការធ្វើខុស ភាពមិនស្មោះត្រង់ ឬអំពើខុសច្បាប់ក្នុងអាជីវកម្ម



ពិភាក្សាជាមួយប្រធានគ្រប់គ្រងផ្ទាល់ ឬប្រធានផ្នែក



ប្រសិនបើការបារម្ភ មានមូលដ្ឋានច្បាស់លាស់ ប្រធានគ្រប់គ្រងផ្ទាល់ ឬប្រធានផ្នែក ត្រូវប្រាប់ទៅអ្នកទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យផ្ទៃក្នុង (RM)



ប្រសិនបើការបារម្ភ មានមូលដ្ឋានច្បាស់លាស់ ប្រធានគ្រប់គ្រងផ្ទាល់ ឬប្រធានផ្នែក ត្រូវប្រាប់ទៅអ្នកទទួលខុសត្រូវ លើការគ្រប់គ្រងហានិភ័យផ្ទៃក្នុង ឬអ្នកទទួលខុសត្រូវលើការកត់ត្រាបញ្ហាផ្ទៃក្នុង។



អ្នកគ្រប់គ្រងហានិភ័យ ឬផ្នែកធនធានមនុស្សពិចារណាពីភាពចាំបាច់ ក្នុងការពិភាក្សាជាមួយម្ចាស់ក្រុមហ៊ុន ដៃគូជាន់ខ្ពស់ ឬប្រធាន និង/ឬអ្នកពាក់ព័ន្ធសំខាន់ៗ ការពិនិត្យឡើងវិញ លើកំណត់ត្រារបស់ម្ចាស់/ដៃគូជាន់ខ្ពស់ នាយកជាន់ខ្ពស់ឬអ្នកពាក់ព័ន្ធសំខាន់ៗ។

## ហេតុអ្វីអាជីវកម្មត្រូវមានគោលនយោបាយស្តីពីការរាយការណ៍ ?

ជារួម គោលនយោបាយ ឬនីតិវិធីស្តីពីការផ្តល់ព័ត៌មានជាសមាសធាតុចាំបាច់ក្នុងស្ថាប័ន ឬក្រុមហ៊ុនមួយ។ បើគ្មានគោលនយោបាយឬនីតិវិធីនេះ ការកែបន្លំ ការប្រព្រឹត្តខុស និងបរាជ័យអាចកើតមានទូទៅក្នុងស្ថាប័ន ឬក្រុមហ៊ុននោះ។ យូរៗទៅ វាអាចបង្កជាផលប៉ះពាល់អវិជ្ជមានលើកេរ្តិ៍ឈ្មោះ និងហិរញ្ញវត្ថុ។ តាមរយៈការបង្កើនទំនាក់ទំនងច្បាស់លាស់ និងការផ្តោតលើគោលដៅរួមរបស់ស្ថាប័នឬក្រុមហ៊ុន គេពិតជាអាចកាត់បន្ថយលទ្ធភាព បង្កគ្រោះថ្នាក់ដល់ស្ថាប័នឬក្រុមហ៊ុនបាន។ នីតិវិធីច្បាស់លាស់ស្តីពីការរាយការណ៍ ក៏ជាគន្លឹះក្នុងការបង្កើតវប្បធម៌សុចរិតភាពក្នុងអាជីវកម្មផងដែរ ព្រោះវាបង្កើនសិទ្ធិអំណាចរបស់និយោជិក ក្នុងការផ្តល់ព័ត៌មាន តាមរយៈការបង្កើតគោលការណ៍ច្បាស់លាស់ពីថ្នាក់លើ។

ប្រភព៖ គោលជំហរគោលនយោបាយ, លេខាធិការដ្ឋានអង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០១០

# ទំនាស់ផលប្រយោជន៍

ក្រុមហ៊ុនគួរបង្កើតគោលនយោបាយ និងនីតិវិធីដើម្បីកំណត់រក ពិនិត្យតាមដាន និងគ្រប់គ្រងទំនាស់ផលប្រយោជន៍ដែលអាចបង្កើតជាហានិភ័យនៃការស៊ីសំណូក (ជាក់ស្តែង អាចកើតឡើង ឬយល់ថាបានកើតឡើង)។

ទំនាស់ផលប្រយោជន៍ គឺជាបញ្ហាជាសកលសម្រាប់ក្រុមហ៊ុនដែលមានគ្រប់ទម្រង់ និងគ្រប់ទំហំ។ នៅពេលផលប្រយោជន៍ឯកជនធំជាងផលប្រយោជន៍ក្រុមហ៊ុន ក្រុមហ៊ុនមានហានិភ័យកាន់តែច្រើនក្នុងការក្លាយជាជនរងគ្រោះនៃអំពើពុករលួយ។ ដូច្នេះ ក្រុមហ៊ុនត្រូវដឹងពីផលប្រយោជន៍ឯកជនរបស់បុគ្គលិកគ្រប់កម្រិត ចាប់ពីថ្នាក់លើដល់ថ្នាក់ក្រោម។ ការណ៍នេះអាចសម្រេចបានតាមរយៈការប្រកាសទ្រព្យសម្បត្តិ និង/ឬ ការប្រកាសផលប្រយោជន៍ ដែលបុគ្គលិករៀបរាប់ពីទ្រព្យសម្បត្តិ ឬតួនាទីផ្សេងទៀតដែលអាចជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួន។ សេចក្តីសង្ខេបស្តីពីធុរកិច្ចនេះ នឹងពន្យល់ពីទស្សនាទាននៃទំនាស់ផលប្រយោជន៍ និងផ្តល់ដល់ក្រុមហ៊ុននូវខ្លឹមសារសង្ខេបនៃគោលនយោបាយល្អប្រសើរស្តីពីទំនាស់ផលប្រយោជន៍។


Phalinn Ooi (Creative Common)

## តើអ្វីជាទំនាស់ផលប្រយោជន៍?

ទំនាស់ផលប្រយោជន៍ ត្រូវបានកំណត់និយមន័យដោយអង្គការតម្លាភាពអន្តរជាតិថាជា "ស្ថានភាពដែលបុគ្គល និងនីតិបុគ្គលដែលពួកគេបម្រើការ មិនថាជារដ្ឋាភិបាល អាជីវកម្ម បណ្តាញផ្សព្វផ្សាយ ឬអង្គការសង្គមស៊ីវិល ត្រូវប្រឈមមុខនឹងការជ្រើសរើសរវាងភារកិច្ច និងតម្រូវការមុខនាទីរបស់ខ្លួន និងផលប្រយោជន៍ឯកជនផ្ទាល់ខ្លួន"។

មាត្រា ៩ ក្នុងច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា (២០១០) កំណត់ទំនាស់ផលប្រយោជន៍ជា "ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍សម្រាប់គ្រួសារ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើទង្វើរបស់ជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន"។

ចំណុចនេះបានក្លាយជាបញ្ហាសម្រាប់ក្រុមហ៊ុន ដោយសារតែផលប្រយោជន៍ល្អបំផុតរបស់ក្រុមហ៊ុន អាចមិនមែនជាអាទិភាពសម្រាប់និយោជិក។ ឧ. ផលប្រយោជន៍សម្រាប់គ្រួសារ ផលប្រយោជន៍អាជីវកម្មផ្ទាល់ខ្លួន និង/ឬទំនាក់ទំនងផ្សេងទៀត នឹងជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្ត។ ការណ៍នេះអាចបង្កើតជាស្ថានភាពដែលក្រុមហ៊ុនទិញទំនិញ ឬ សេវាក្នុងតម្លៃខ្ពស់ ប៉ុន្តែមានគុណភាពទាប ដោយសារតែផលប្រយោជន៍ឯកជនរបស់អ្នកទទួលខុសត្រូវលើការទិញទាំងនោះ។

ស្ថានភាពទំនាស់ផលប្រយោជន៍ អាចកើតឡើងនៅពេលអ្នកទទួលខុសត្រូវផ្នែកលទ្ធកម្មទទួលបានអំណោយ ឬកម្រៃជើងសារជាថ្នូរនឹងការអនុគ្រោះដល់អ្នកផ្គត់ផ្គង់ក្រុមហ៊ុន។ គេត្រូវចាំថា អំពើពុករលួយមានទម្រង់ជាច្រើន។ សាច់ប្រាក់ អំណោយ និងការសន្យាផ្តល់ការអនុគ្រោះ សុទ្ធតែជាទម្រង់នៃអំពើពុករលួយ។



Phalinn Ooi (Creative Common)

# គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍

ចំណុចចាប់ផ្តើមសម្រាប់នីតិវិធីរឹងមាំ ស្តីពីទំនាស់ផលប្រយោជន៍ គឺការកំណត់និយមន័យ និងវិសាលភាព ដោយសារតែលក្ខណៈស្មុគស្មាញនៃទំនាស់ផលប្រយោជន៍ត្រូវមានការកំណត់និយមន័យច្បាស់លាស់រួមទាំងឧទាហរណ៍។ ក្រុមហ៊ុនត្រូវធានាថា បុគ្គលិកបានដឹងច្បាស់ពីអ្វីដែលត្រូវបានបែងចែកជាទំនាស់ផលប្រយោជន៍ជាពិសេសក្នុងមជ្ឈដ្ឋានអាជីវកម្មនៅកម្ពុជាដែលអំណោយ និងកម្រៃជើងសារមានលក្ខណៈទូទៅបំផុត។ ក្នុងគោលនយោបាយនេះ គេត្រូវគូសបញ្ជាក់ថា បុគ្គលិកទាំងអស់ត្រូវធ្វើការប្រកាសទំនាស់ផលប្រយោជន៍ ក្រោយចូលបម្រើការក្នុងក្រុមហ៊ុន និង/ឬចាប់ពីថ្ងៃដែលគោលនយោបាយនេះត្រូវបានអនុវត្ត។ ក្រៅពីនេះ បុគ្គលិកគួរប្រកាសថាតើអាចមានករណីទំនាស់ផលប្រយោជន៍កើតឡើងឬទេ។ គោលនយោបាយនេះគួរត្រូវបានពិនិត្យតាមដាន ហើយបុគ្គលិកគួរធ្វើការប្រកាសប្រចាំឆ្នាំពីផលប្រយោជន៍ និងដាក់ជូនផ្នែកធនធានមនុស្ស ដែលធានាថាបុគ្គលិកគ្រប់រូបធ្វើការប្រកាសទាន់ពេលវេលា និងជូនដំណឹងដល់ប្រធាន ឬថ្នាក់គ្រប់គ្រងពាក់ព័ន្ធស្តីពីការប្រកាសរបស់បុគ្គលិក។

ដើម្បីឲ្យគោលនយោបាយនេះមានប្រសិទ្ធភាព គេត្រូវមានទណ្ឌកម្មដែលមានចាប់ពីការព្រមានជាលាយលក្ខណ៍អក្សររហូតដល់ការបណ្តេញចេញ ទៅតាមភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តខុស។

## អត្ថប្រយោជន៍នៃការមានគោលនយោបាយ ស្តីពីទំនាស់ផលប្រយោជន៍

អត្ថប្រយោជន៍ភ្លាមៗនៃការមានគោលនយោបាយ ស្តីពីទំនាស់ផលប្រយោជន៍ គឺការការពារផលប្រយោជន៍ល្អបំផុតរបស់ក្រុមហ៊ុន។ នៅពេលមានគោលនយោបាយនេះ ក្រុមហ៊ុនអាចបញ្ចៀសមិនឲ្យបុគ្គលិកប្រើប្រាស់ក្រុមហ៊ុនដើម្បីជាប្រយោជន៍ឯកជន។ ការណ៍នេះ នឹងជួយសង្គ្រោះប្រាក់លទ្ធកម្មរបស់ក្រុមហ៊ុន និងធានាថាសេវា ឬបុគ្គលិកត្រូវបានជ្រើសរើសទៅតាមគុណសម្បត្តិ ជាជាងទំនាក់ទំនង។ គោលនយោបាយល្អប្រសើរស្តីពីទំនាស់ផលប្រយោជន៍នឹងជួយឲ្យបុគ្គលិកបញ្ចៀសស្ថានភាព ដែលពួកគេអាចបង្កជាទំនាស់ផលប្រយោជន៍បាន។ នេះជាប្រការសំខាន់សម្រាប់ការរក្សាបរិយាកាសការងារល្អប្រសើរ ព្រោះថាទំនាស់ផលប្រយោជន៍ដែលអាចកើតឡើង បង្កផលប៉ះពាល់អវិជ្ជមានលើសីលធម៌បុគ្គលិក។ ក្នុងមជ្ឈដ្ឋានដែលមានហានិភ័យខ្ពស់នៃអំពើពុករលួយដូចនៅកម្ពុជា គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ គឺជាឧបករណ៍ដ៏ល្អបំផុតក្នុងការគ្រប់គ្រងហានិភ័យអំពើពុករលួយផ្ទៃក្នុង បង្កើនការយល់ដឹង និងកាត់បន្ថយលទ្ធភាពដែលបុគ្គលិកប្រើប្រាស់ក្រុមហ៊ុនដើម្បីប្រយោជន៍ឯកជន។ គន្លឹះក្នុងការអនុវត្តគោលនយោយស្តីពីទំនាស់ផលប្រយោជន៍ដោយជោគជ័យគឺការដាក់ទណ្ឌកម្មច្បាស់លាស់លើបុគ្គលិកដែលមិនអនុវត្តតាម និងការពិនិត្យតាមដានជាប្រចាំលើផលប្រយោជន៍របស់បុគ្គលិកតាមរយៈកាតព្វកិច្ចប្រកាសផលប្រយោជន៍។ គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ គឺជាចំណុចចាប់ផ្តើមដ៏ល្អសម្រាប់ក្រុមហ៊ុន ដែលចង់កាត់បន្ថយចំណាយទូទៅ និងចំណាយផ្សេងទៀត និងបង្កើតវប្បធម៌សុចរិតភាព។

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អង្គការតម្លាភាពកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ៣ ផ្លូវ៣៩០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២១៤ ៤៣០   គេហទំព័រក្នុងប្រទេស ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្ដាល៖ www.transparency.org

រក្សាសិទ្ធិដោយ អង្គការតម្លាភាពកម្ពុជា ២០១៧